

ឧបសៅសង្ហា

# អត្ថរូបពីរយ៉ាង នៃរាជានិយមខ្មែរ



ពិនិត្យឡើងវិញអំពីព្រឹត្តិការណ៍សំខាន់ៗមាននៅក្នុងប្រវត្តិសាស្ត្រខ្មែរ

## មាតិការឿង

អារម្ភកថា ........ 2
អត្ថរូប នៃលទ្ធិទេវរាជ ........ 3
អត្ថរូប នៃរាជានិយមពុទ្ធគារវតា ........ 7
សេចក្ដីសន្និដ្ឋាន ........ 11

# អារម្ភកថា

រាជានិយមខ្មែរ ទោះបីពួកអ្នកប្រឆាំង ចង់ឬមិនចង់ ជារបបមួយបានកសាង មហិទ្ធានុភាព នៃស្រុកខ្មែរ។ ឧទ្ទង្គត គឺសម័យមហានគរ : ៥ សតវត្ស (សតវត្សទី៨ ដល់ ទី១៣) ក្នុងការវិវត្តន៍រហ័ស ពីឋានៈនគរចម្រុះ នៃពួកកុលសម្ព័ន្ធ រហូតដល់នគររៀបចំ មានឯកភាពជាតិ ផ្អែកលើព្រាហ្មណ៍សាសានា ជាវិធី នៃគំនិត នៃការដឹកនាំជាតិ។ ដើមសតវត្សទី៣ ព្រះបាទ ហ៊ុន ទៀន នាំព្រហ្មញ្ញសាសនាចូលមកស្រុកខ្មែរ ហើយ ព្រះអង្គ ធ្វើបរិវត្តសង្គមចាស់ ឱ្យទៅជាសង្គមអារ្យៈ ដោយរក្សាឫសមូលដ្ឋានណា ដែលទុកជាដើមកំណើត នៃសង្គមខ្មែរ។ ដើមសតវត្សទី៩ ព្រះបាទ ជ័យវរ្ម័នទី២ (៨០២-៨៥០) បន្ទាប់ពីបានធ្វើសង្គ្រាមជេស្ឋជ័យ បង្រួបបង្រួមជាតិរួចមក ព្រះអង្គ រៀបចំរដ្ឋឱ្យមានបទដ្ឋាន នៃរដ្ឋបាលតែមួយ ដើម្បី សំរួល នូវការគ្រប់គ្រង នៃកិច្ចការរាជការ, ឯកសណ្ឋានភាព នៃជំនឿសាសនា ដោយយកលទ្ធិទេវរាជ[1] ជាកម្លាំងចូលរកមជ្ឈមណ្ឌល ដើម្បី រាស្ត្រគ្រប់មជ្ឈដ្ឋាន និង គ្រប់ស្រទាប់ ទោះបីខ្លួន មានជំនឿបែបណាក៏ដោយ ឱ្យមកនៅក្រោម

[1] និមិត្តរូប នៃទេវរាជ គឺ សិវលិង្គ ដែលគេសន្មត់ថាបានមកពីព្រះឥសូរ តាមរយៈព្រាហ្មណ៍។ ដូច្នេះ ក្រោយពីធ្វើពិធីអភិសេក ព្រះបាទជ័យវរ្ម័នទី២ ដោយព្រាហ្មណ៍ សិវកៃវល្យ ព្រះអង្គ ក៏ក្លាយជាព្រះឥសូរបែងភាគ។

បារមី ព្រះមហាក្សត្រ មានឋានៈជា ចក្រវាតិន (ស្តេចចក្រវាល)។ រាជបដិវត្តន៍ ទាំងពីរយ៉ាងនេះ គឺនៅក្នុងគោលដៅតែមួយ គឺធ្វើឱ្យមាន សមតាភាព នៅក្នុងសង្គម និង សន្តិភាព នៅក្នុងរាជនគរ។

## អត្ថរូប នៃលទ្ធិទេវរាជ

នុះ ជាមូលដ្ឋាន នៃទ្រឹស្តី នៃលទ្ធិទេវរាជ នៃរាជានិយមខ្មែរ ដែលគរ នៅក្នុងប្រវត្តិសាស្ត្រជាតិ សំរាប់គាំពារ នូវប្រយោជន៍ នៃលទ្ធិនោះ គឺ : ឯកភាពជាតិ និង សន្តិភាព។

ឯកភាព ជា សង្គហកម្ម[2] ដែលជានាទីផ្តាច់មុខ របស់ព្រះមហាក្សត្រ។ ដូច្នេះ ព្រះអង្គ ជាអ្នករក្សាទុក នូវនាទីនេះតែម្នាក់ឯង លើលោកនេះ, អាស្រ័យហេតុនេះ គឺត្រូវចាត់ទុកព្រះអង្គ ជាទេវរាជ ដែលមនុស្ស ត្រូវតែកោតខ្លាច។ តែស្តេចទេវរាជ ព្រះអង្គ មិនដែលប្រើរាជអំណាច យកទៅរំលោភ លើប្រជារាស្ត្រនោះឡើយ។ ព្រះអង្គ ជាស្តេចល្អឥតខ្ចោះ, ជាស្តេចយុត្តៈ ដោយសុក្រិត និង ដោយអធិបតេយ្យ ; ព្រះអង្គ គ្រប់គ្រងនគរ ដោយជាក់លាក់ ដូចអាទិទេព គ្រប់គ្រងចក្រវាល ដើម្បី រក្សា សណ្តាប់ធ្នាប់លោកីយ៍ និង ឯកភាព។

2 សង្គហកម្ម : ការធ្វើសេចក្តីសង្គ្រោះ។

តែត្រូវដឹងថា នៅក្នុងប្រវត្តិសាស្ត្រជាតិខ្មែរ មានកង្វះ នូវការពិត នៃស្ថានភាព នៃការរស់នៅ របស់ប្រជារាស្ត្រខ្មែរ។ រូបចម្លាក់ លើផ្ទាំងជញ្ជាំង នៃប្រាង្គប្រាសាទ អង្គរវត្ត បង្ហាញ នូវទិដ្ឋភាព អធិកអធម នៃក្បួនយោធា និង សង្គ្រាមជេដ្ឋជ័យ ដែលជានិមិត្តរូប នៃរាជមហិទ្ធានុភាព ឆ្លាក់លើសីលា សំរាប់ចិរកាល។ សួរថា តើសេចក្តីថ្កុំថ្កើង នៃរូបភាពទាំងនោះ មានការទាក់ទងអ្វីនឹងសុភមង្គល នៃប្រជារាស្ត្រ ? តើ លទ្ធិទេវរាជផ្អែកលើ ឯកភាពជាតិ និង សន្តិភាព មាន យុត្តិធម៌ នៃមនុស្សលោក សំរាប់ប្រជារាស្ត្រដែរឬទេ ? តើ ទេវយុត្តិធម៌ និង នរៈយុត្តិធម៌ វាជាយុត្តិធម៌តែមួយ សំរាប់មនុស្សលោក ?

គ្រប់សំនួរទាំងឡាយនោះ វាអាចទុកជា ពាក្យបណ្តាសា ចំពោះលទ្ធិទេវរាជ ព្រោះហាក់បីដូចជាទុក រាជករុណា និង សេចក្តីស្នេហា របស់ព្រះមហាក្សត្រ ចំពោះរាស្ត្រ ផ្ទុយនឹងរាជយុត្តិធម៌។ យុត្តិធម៌ វាមាននៅក្នុងធាតុ នៃអាទិទេព ព្រោះព្រះអង្គ ជាអ្នកបង្កើតលោក ហើយស្តេចទេវរាជ ជាតំណាង នៃព្រះអង្គ នៅលើផែនដី នៃមនុស្សា ហើយ តាមរយៈផ្សព្វ[3]នេះ វាជា កម្លាំងពហុផល បង្កើត នូវសេចក្តីរីករាយ និង ភិយ្យោភាព សំរាប់ប្រជារាស្ត្រ, តើការណ៍ហ្នឹង វាមិនមែនជាយុត្តិធម៌ ដូច្នោះទេឬ ? វិធី នៃគំនិតបរិសុទ្ធ

3 ផ្សព្វ, ការប៉ះពាល់ត្រូវ។

ជាអាទិទេព ព្រោះសិល្បៈ នៃអាទិទេព គឺជាសិល្បៈ នៃសទ្ធិន្ទ្រិយ (មេត្តានៅក្នុងបេះដូង) ដោយសុខដុមយ៉ាងជ្រៅបំផុត ដែលបញ្ចេញ ជារូបភាពគំនិត ជាជំនឿ នៃប្រជារាស្ត្រ ដែលវានាំ បង្កើតឱ្យមាន នូវសេចក្តីស្នេហា ដោយមេត្រីភាព ចំពោះស្តេចទេវរាជ ទោះបីនៅក្នុង លក្ខខណ្ឌបែបណាក៏ដោយ គឺថា នៅក្នុងឱវាទ នៃរាជអំពើ វិជ្ជមាន និង អវិជ្ជមាន ព្រោះ ស្តេចទេវរាជ ព្រះអង្គ មិនដែលប្រព្រឹត្តអ្វីខុសនោះឡើយ។ ដូច្នេះ ព្រះអង្គ មិនមែនជា នីតិជន (sujet du droit) នោះទេ, បើនិយាយឱខ្លី គឺ ព្រះអង្គ និង នីតិ វាតែមួយ ព្រោះ ព្រះអង្គ ជាតំណាង នៃអាទិទេព។ នៅក្នុងទេវលក្ខខណ្ឌនេះ តើស្តេចទេវរាជ ទ្រង់ធ្វើការវិនិច្ឆ័យទោស និង មាននីតិគំនិត ដូចម្តេច ចំពោះ ប្រជារាស្ត្រ ? ដ្បិត ប្រជារាស្ត្រ ជាមនុស្សលោក។ ហេតុអ្វី ក៏ត្រូវបំបែកលក្ខន្តិកៈ រវាង ស្តេច និង រាស្ត្រ ខុសគ្នាឆ្ងាយបែបនេះ នៅក្នុងលោកតែមួយ ? ឆ្លើយថា : ព្រោះ លទ្ធិទេវរាជ ជាសាសនា។ សួរថា : តើមានដែរឬទេ សាសនា នៅក្នុងលោកនេះគ្មាន យុត្តិធម៌ និង មនុស្សធម៌ ? ឆ្លើយថា : ច្បាប់ របស់ស្តេច គឺជា ការប្រកួតកម្លាំង, ច្បាប់អរូបី។ សួរថា : តើច្បាប់បែបនេះ អាចនឹងដោះស្រាយ បញ្ហាសង្គម និង ជីវិត នៃប្រជារាស្ត្រ បានដែរឬទេ ?

តែ មហានគរខ្មែរ នៅក្រោមលទ្ធិទេវរាជ ដួលរលំបន្តិចម្តងៗ រហូតរលត់សូន្យ។ នោះជា ទុរគត និង សុញ្ញភាព នៃ

លទ្ធិទេវរាជ, តែ ឫទ្ធានុភាព នៃស្តេចទេវរាជ វិញ វានៅមានក្នុងផ្គត់គំនិតខ្មែរជានិច្ច ទោះបី មានប្តូរ របបដឹកនាំ ពី លទ្ធិទេវរាជ មកជារាជានិយមពុទ្ធគារវតា[44]។ ចាប់ពីផែនដី ព្រះបាទជ័យវរ្ម័នទី៧ (១១៨១-១២១៨ ?) របបរាជានិយមខ្មែរ មានការវិវត្ត ទៅរកពុទ្ធគារវតា តែសាសនាព្រាហ្មណ៍ នៅមានឥទ្ធិពលខ្លាំងគួរសមជានិច្ចនៅក្នុងវណ្ណៈក្សត្រ និង អភិជន ដូចយ៉ាង ព្រះបាទជ័យវរ្ម័ន ទី៧ ទោះបី ព្រះអង្គជាពុទ្ធសាសនិក តែព្រះអង្គ ក៏នៅមានព្រាហ្មណ៍បុរោហិត ជាព្រះគ្រូ របស់ព្រះអង្គ។ ដូចគ្នានឹងព្រះបាទត្រសក់ផ្អែម (១៣៤០-?) ជាព្រះមហាក្សត្រពុទ្ធគារវតាទាំងមូល និង ជាអ្នកបង្កើតសន្តតិវង្សថ្មី តែព្រះអង្គ ប្រត្យាស្ថាបនាឡើងវិញផងដែរ នូវក្រុមព្រាហ្មបុរោហិតស្របតាមរាជានិយម និយមព្រាហ្មញ្ញសាសនា។ ដូច្នេះ នៅក្នុងគំនិត នៃរាជានិយមខ្មែរ ទុកព្រាហ្មញ្ញសាសនា មិនគ្រាន់តែជាជំនឿសាសនា គឺទុកជា គ្រឹះនៃស្ថាប័នតែម្តង។ រហូតមកដល់សព្វថ្ងៃ គ្រប់រាជពិធីសំខាន់ៗនៅក្នុងព្រះបរមរាជវាំង គឺពួកព្រាហ្មណ៍បុរោហិត ជាអ្នកដឹកនាំ។

[44] ពុទ្ធគារវតា គឺ សេចក្តីគោរពចំពោះព្រះពុទ្ធ។

## អត្ថរូប នៃរាជានិយមពុទ្ធគារវតា

ការប្តូរជាស្ថាពរ ពីលទ្ធិទេវរាជ មកលទ្ធិពុទ្ធគារវតា គឺធ្វើតាមផ្លូវបដិវត្តន៍ នៅក្នុងមជ្ឈដ្ឋាន នៃពួកអ្នកដឹកនាំ។ នៅក្នុងបដិវត្តន៍នោះ មានការធ្វើឃាត ព្រះមហាក្សត្រចុងក្រោយបង្អស់ នៃសន្តតិវង្សអង្គរ ព្រះបាទជ័យវរ្ម័នទី៩ (១៣២៧-១៣៤០)។ តាមរាជពង្សាវតារ អ្នកធ្វើឃាត គឺតាត្រសក់ផ្អែម ជាអ្នកថែសួនច្បារ របស់ព្រះមហាក្សត្រ, ជាឃាតកម្មដោយគ្រោះថ្នាក់។ អ្នកប្រវត្តិសាស្ត្រ នៅមិនទាន់ឆ្លើយបាននូវសំនួរថា : តើអ្វីខ្លះជាមូលហេតុនៃបដិវត្តន៍ ? បើតាមទស្សនៈ របស់លោក Adhémard Leclere និង Dauphin Meunier : ព្រឹត្តិការណ៏ ព្រះបាទត្រសក់ផ្អែមឡើយសោយរាជ្យ គឺជាមហាបដិវត្តន៍មួយក្នុងប្រវត្តិសាស្ត្រខ្មែរ ហើយបដិវត្តន៍នោះ គឺជាបដិវត្តន៍ ខាង នយោបាយ និង ខាង សាសនា។

ប្រាកដណាស់ហើយថា លទ្ធិទេវរាជ នៃរបបរាជានិយម ធ្វើការកសាងជាតិខ្មែរ ឱ្យបានដល់ ភាពរុងរឿងត្រចេះត្រចង់បំផុតក្នុងប្រវត្តិសាស្ត្រខ្មែរ។ ភាពរីកចំរើននោះ តើសំរាប់តែ វណ្ណៈក្សត្រ និង អភិជន ? ចំណែកឯរាស្ត្រ រស់នៅក្នុងភាពទ័លច្រក រវាង ភាពក្រលំបាក និង ភារិយកម្មគ្រប់បែបយ៉ាង ហើយ ក្រៃពេក ដូចយ៉ាង កំណែនយោធា និង កំណែនសំណង់ប្រាសាទ។ ទុក្ខវេទនានេះឯង ដែលនាំ

អោយប្រជារាស្ត្រ យកព្រះពុទ្ធសាសនា ជាជម្រកចិត្ត ដើម្បីបន្ធូយ នូវទុក្ខលំបាក របស់ខ្លួន។ តែមាន រាជសិលាចារឹកដ៏ល្បីមួយ របស់ព្រះបាទជ័យវរ្ម័នទី៧ ចារថា « ទុក្ខ នៃប្រជារាស្ត្រ គឺជាទុក្ខ របស់ព្រះមហាក្សត្រ »។ ប្រយោគនេះបង្ហាញ នូវករុណា របស់ព្រះមហាក្សត្រ ចំពោះការរងទុក្ខវេទនា របស់ប្រជារាស្ត្រ។ រាជមេត្តាធម៌នេះ បញ្ជាក់លើស្នាដៃ របស់ព្រះអង្គ នូវសំណង់មន្ទីរពេទ្យ ចំនួន ១០២ សំរាប់ព្យាបាលជម្ងឺ នៃប្រជារាស្ត្រ និង សំណង់ សាលាសំណាក់ (ធម៌សាលា) ចំនួន ១២១ សំរាប់សំរួល នូវផាសុកភាព ដល់អ្នកធ្វើដំណើរ នៅក្នុងព្រះរាជនគរ។ ព្រះអង្គ ជាអ្នកបង្គាប់ ឱ្យសាងប្រាសាទបាយ័ន សំរាប់តំកល់ បដិមាពុទ្ធអង្គយ៉ាងធំ កំពស់ជិត ៤ម.។ សួរថា : តើ កាប្តូរ លទ្ធិ នោះវាមានប្តូរទាំងស្រុក នូវអត្ថរស់ នៃរបបរាជានិយម ដែរឬទេ ?

គេថា សាសនា នៃព្រះគុណ[5] និង របបដឹកនាំ នៃព្រះគុណនៅក្នុងដៃ របស់វណ្ណៈ នៃអ្នកដឹកនាំ វាស្រដៀងគ្នាណាស់។ ព្រះគុណ គឺជាអត្ថរូប នៃការទួលសុំទាន នៃអ្នកសុំទាន គឺប្រជារាស្ត្រ និង ការផ្តល់ទាន នៃអ្នកផ្តល់ទាន គឺព្រះមហាក្សត្រ។ ដូច្នេះ តើវាមានខុសគ្នាអ្វីទៅ ពីលទ្ធិទេវរាជ បើព្រះមហាក្សត្រ នៅតែជាអ្នកផ្តល់ទាន ដល់ប្រជារាស្ត្រ ? បើ

---

5 សាសនា នៃព្រះគុណ : Religion de la grâce.

ទុកការប្តូរ នៃលទ្ធិនោះ ជាបដិវត្តន៍ សំរាប់គ្រាន់តែកែលំ លួ នូវអត្តរូប នៃលទ្ធិ តែនៅតែរក្សា នូវអត្តរស់ នៃលទ្ធិ ទាំងមូល, សួរថា តើនៅត្រង់ចំណុចណាខ្លះ ដែរអាច ទុកជា ការដូរ ជាអំណោយផល ចំពោះប្រជារាស្ត្រ ? អត្តរូប នៃស្តេចទេវរាជ និង ស្តេចពុទ្ធគាររវតា នៅក្នុងអត្តរស់ នៃ វណ្ណៈ ជាអ្នកដឹកនាំដាច់មុខតែមួយ វាស្រដៀងគ្នាណាស់។ រាស្ត្រពុទ្ធសាសនិក និង ស្តេចពុទ្ធសាសនិក វាមិនរលាយ ចូលគ្នាបាននោះឡើយ ព្រោះវាមានរបងវណ្ណៈ ជាខណ្ឌសី មា។ ដូចយ៉ាង នៅក្នុងបដិវត្តន៍ របស់តាត្រសក់ផ្អែម ដែលគេទុកជាបដិវត្តន៍ ខាងសាសនា តែអ្វីដែលតា ត្រសក់ផ្អែម គាត់ស្តារលំដាប់ជាប្រញាប់ គឺ អត្តរូប និង អត្តរស់ នៃរបបរាជានិយមចាស់ គឺថា គាត់រក្សាវណ្ណៈក្សត្រ និង លំដាប់ នៃការដឹកនាំ នៃវណ្ណៈទាំងមូល។ ដូច្នេះ ព្រះបាទត្រសក់ផ្អែម ជារាស្ត្រ យកតម្រាប់ វណ្ណៈក្សត្រ ដែល ជាវណ្ណៈ មានព្រះគុណ ដល់ប្រជារាស្ត្រ តាមក្បួន នៃព្រះ ករុណាដដែល។ ទសពិធរាជធម៌ វាគ្រាន់តែជា បទដ្ឋាន នៃឧត្តមគតិ សំរាប់ស្តេចពុទ្ធគាររវតា តែមិនទុកជា រាជ កាតព្វកិច្ចដាច់ខាត ដូច្នេះ ព្រះអង្គ ទ្រង់មិនមែន ជា អ្នកទទួលខុសត្រូវ លើអំពើ នៃការដឹកនាំ របស់ព្រះអង្គ នោះឡើយ។ ជាការពិត នៅក្នុងទស្សនៈ នៃស្តេចពុទ្ធគាររ តា បញ្ជាក់ថា : ទុក្ខ របស់ប្រជារាស្ត្រ គឺជាទុក្ខ របស់ព្រះ មហាក្សត្រ តែ អត្តរស់ នៃទុក្ខ នៅក្នុងជំនឿគ្រឹះ នៃពុទ្ធ

សាសនា គឺកើតពី « កម្មផល » ដែលជាផលា នៃអំពើរបស់បុគ្គលម្នាក់ៗផ្ទាល់ គ្មានអ្នកដទៃ អាចជួយសង្គ្រោះបាននោះទេ។ នៅចំពោះមុខ បដិមាពុទ្ធគ្រប់រូបធាតុ រាស្ត្រពុទ្ធសាសនិក បន់ស្រន់ សុំវិញ្ញាណ នៃព្រះពុទ្ធ ឱ្យព្រះអង្គជួយថែរក្សា និង ការពារខ្លួន ក្នុងឋានៈព្រះអង្គ ជាអ្នកសង្គ្រោះ នៃមនុស្ស នៅក្នុងលោក។ តែ ជារាស្ត្រគជុន[6] ជាពុទ្ធសាសនិក ក៏សុំ ព្រះមហាក្សត្រពុទ្ធគារវតា នូវសេចក្ដីមេត្តាអាសូរពីព្រះអង្គ ក្នុងឋានៈព្រះអង្គជាបិតា នៃប្រជារាស្ត្រ : « ខ្ញុំជាបថុជ្ជន ជាអ្នកគោរពព្រះពុទ្ធធម៌ឥតខ្ចោះ ជាអ្នករស់នៅក្រោមបារីតែមួយ នៃព្រះមហាក្សត្រ និង ជាអ្នកបំរើគ្មានលក្ខខណ្ឌ ខ្ញុំសុំឱ្យព្រះធម៌ និង ព្រះរាជបារមី មេត្តាផ្ដល់ នូវសេចក្ដីសុខ គ្រប់បែបយ៉ាងដល់ខ្ញុំ ក្នុងឋានៈព្រះទាំងពីរ ជាម្ចាស់ នៃជីវិតលើត្បូង និង ម្ចាស់ នៃវាសនា នៃសត្វលោក និង រាស្ត្រ ! »។

ទោះបីរាស្ត្រ ខំបន់ស្រន់យ៉ាងណាក្ដី តែទុក្ខ របស់គាត់ វាមិនរលត់សោះ ផ្ទុយទៅវិញ វាកាត់តែធ្ងន់ធ្ងរឡើង ព្រោះថាការសុំតាមការបន់ស្រន់ វាមិនមែន ជាដំណោះស្រាយ ឬមហោសថ នោះទេ។ ពាហនសត្វ វាហត់នឿយខ្លាំង លែងដើបដើរបាន ដូច្នេះវាដេក រង់ចាំសេចក្ដីស្លាប់ មិនអាចបំរើ នូវសេចក្ដីត្រូវការ របស់ម្ចាស់វាបានទៀតឡើយ។ រាស្ត្រ

[6] រាស្ត្រគជុន : រាស្ត្រ ជាកូន (ស្រីប្រុស), peuple enfant.

មានម្ចាស់ ក៏ដូចគ្នានឹងពាហនសត្វនោះដែរ បើខ្លួនមាន ទុក្ខ តែមិនរកដំណោះស្រាយ តាមមធ្យោបាយ របស់ខ្លួន ឯង។

## សេចក្តីសន្និដ្ឋាន

ការប្តូរពី លទ្ធិទេវរាជ មក លទ្ធិពុទ្ធគារវតី វាគ្រាន់តែជា ការប្តូរ នៃអត្តរូប របស់រាជានិយមខ្មែរតែប៉ុណ្ណោះ ព្រោះ របបរាជានិយម នៅរក្សាធាតុអំណាចទាំងមូល របស់ខ្លួន គឺអំណាចសមស្ត[7]។ មែនពិត វាមានរូបភាព ជាបដិវត្តន៍ សាសនា និង នយោបាយ តែវាគ្រាន់តែជាបដិវត្តន៍ សំរាប់ លំអ វណ្ណៈ នៃពួកអ្នកដឹក ព្រោះ គ្មានការចូលរួមពីប្រជារា ស្ត្រនោះទេ ដ្បិតនៅក្នុងបដិវត្តន៍នោះ វាគ្មានមានគោល ការណ៍ នៃនីតិ គឺជា អធិបតី នៅក្នុងលោកនោះឡើយ។ ពី ព្រះបាទជ័យវរ្ម័នទី៧ មកដល់ ព្រះបាទត្រសក់ផ្អែម ស្រុក ខ្មែរ កំពុងរំអិល លើជម្រាលចុះ។ សិរីរុងរឿង របស់ស្រុកខ្មែរ ដែលជាស្នាដៃ របស់ព្រះបាទជ័យវរ័ន្មទី៧ និង ការស្តារ នៃ តម្លៃ នៃរាជានិយម ដែលជាស្នាដៃ របស់ព្រះបាទត្រសក់ ផ្អែម តាមការបដិវត្តន៍ នៃលទ្ធិសាសនា វាមិនអាចប ញ្ច្រាស នូវជម្រាលចុះបាននោះទេ ដែលនាំឱ្យបក្សពួក

7 អំណាចសមស្ត ជាអំណាច បង្ខំ ប្រជាពលរដ្ឋ ឲធ្វើតាម មនោគមវិជ្ជារបស់ អ្នកដឹកនាំ។

ទាំងសងខាង ដាក់កំហុសគ្នាទៅវិញទៅមក។ ពួកខាងនិយមលទ្ធិទេវរាជ និន្ទាថាស្រុកខ្មែរចុះអន់ថយ ដោយសារព្រះពុទ្ធសាសនា ដែលជាសាសនា នាំប្រជារាស្ត្រ ឱ្យគិតតែស្វែងរកផ្លូវនិព្វាន ដែលនាំឱ្យជនខ្មែរទាំងឡាយ បាត់អស់ នូវសេចក្តីក្លៀវក្លា ជាអ្នកការពារជាតិ។ ចំណែក ពួកអ្នកនិយមលទ្ធិពុទ្ធគារវតា វិញ យល់ឃើញថា លទ្ធិទេវរាជគិតតែ ធ្វើការកសាង លិង្គព្រះឥសូរ សំរាប់គោរពបូជាហើយ កេណ្ឌប្រជារាស្ត្រ ធ្វើជាកម្មករសំណង់ប្រាសាទ សំរាប់អាទិទេព។ តែបក្សពួកទាំងសងខាង មិនធ្វើការទិតៀនរបៀបគ្រប់គ្រង នៃរបបរាជានិយមនោះទេ។ ហេតុអ្វី ? ព្រោះថា បក្សពួកទាំងសងខាងនោះ ជាថ្នាក់អ្នកដឹកនាំទទួលបាន បុព្វសិទ្ធិគ្រប់បែបយ៉ាង ពីប្រភពតែមួយ គឺតួស្ថាប័ទព្រះមហាក្សត្រ។ ដូច្នេះ ដូរលទ្ធិសាសនា មិនមានន័យថា ត្រូវដូរ របបដឹកនាំនោះឡើយ ហើយ ដូរព្រះមហាក្សត្រ ក៏មិនមានន័យថា ដូរស្ថាប័នព្រះមហាក្សត្រ នោះដែរ។ យើងអាចសន្និដ្ឋានបានថា ដើមជម្លោះ គឺជាវិវាទ រវាងវណ្ណៈព្រាហ្មណ៍ និង វណ្ណៈមន្ត្រី ដែលជាសម្ពន្ធមិត្តឯកសិទ្ធិរបស់វណ្ណៈក្សត្រ។ ត្រូវដឹងថា វណ្ណៈសេនាមន្ត្រី នាំគ្នាជ្រើសយកពុទ្ធសាសនា ដើម្បី ប្រឆាំងនឹង ពួកព្រាហ្មបុរោហិតដែលភាគច្រើន មានដើមកំណើតបរទេស។ តើជាវិវាទមានជម្មជាតិប្រកាន់ពូជសាសន៍ ? មិនមែនទេ។ មូលហេតុ នៃជម្លោះ គឺស្ថិតនៅលើ ការដណ្តើមគ្នា យកអំណាច

ដើម្បីមានឥទ្ធិពល ទៅលើព្រះមហាក្សត្រ។ ជាវណ្ណៈទី១ នៅក្នុងព្រាហ្មញ្ញសាសនា ពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យ និង ពួកព្រាហ្មណ៍បុរោហិត មានអារម្មណ៍ថាពួកខ្លួន មានអំណាចសាសនាទាំងមូល ទៅលើស្តេចទេវរាជ ដូច្នេះហើយ បានជាពួកខ្លួន ស្ទើរតែបង្គាប់ព្រះមហាក្សត្រ ឱ្យកសាងប្រាសាទគ្រប់បែបយ៉ាង ដើម្បីថ្វាយដល់ព្រះអាទិទេព របស់ពួកខ្លួន ដែលជាសំណង់ មានតម្លៃថ្លៃដល់ថវិកាជាតិ និងជីវិត នៃប្រជារាស្ត្រ។ អំណាចប្រកបដោយគ្រោះថ្នាក់បែបនេះ ធ្វើឱ្យពួកមហាសេនាមន្ត្រី ស្ទើរបាត់អស់ នូវអំណាចនៃឥទ្ធិពល ទៅលើព្រះមហាក្សត្រ ព្រោះព្រះអង្គ ស្តាប់តែយោបល់ ពួកព្រាហ្មណ៍បុរោហិត មិនត្រឹមតែ កិច្ចការសាសនា គឺរហូតដល់កិច្ចការរាជការ ហើយទុកការទាយរបស់ព្រាហ្មណ៍ រាជហោរាធិបតិ ជាទំនាយសម្មតសច្ចៈ[8]។ បន្តិចម្តងៗ នៅក្នុងអំឡុងច្រើនសតវត្ស កំហឹងកំបាំងរបស់ពួកមហាមន្ត្រីមួយចំនួនធំ ជាពុទ្ធសាសនិក ចំពោះពួកព្រាហ្មណ៍បុរោហិត ក្លាយជាទំនាស់ចេញមុខ នាំបង្កើតឱ្យមានវិវាទសាសនា នៅក្នុងវង់ នៃវណ្ណៈមន្ត្រីផង វណ្ណៈក្សត្រផង។ ព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គ មានប្រផ្នូលអំពី

8 នៅក្នុងប្រវត្តិសាស្ត្រខ្មែរនៅក្រោយសម័យអង្គរ មានសរសេររិះគន់ច្រើន អំពីឥទ្ធិពល នៃការទាយរបស់ព្រាហ្មណ៍ ជាហោរាបុរោហិត ទៅលើព្រះមហាក្សត្រ ដែលនាំឱ្យព្រះអង្គ ធ្វើការសម្រេចខុស ដូចយ៉ាង នៅក្នុងរាជ ព្រះស្តេចកន (១៥០៥-១៥១៥) និង ព្រះបាទបទុមរាជាទី២ ឬ ព្រះបាទរាមាធិបតីចន្ទ (១៦៤២-១៦៥៨)។

*(note de bas de page - suite)*

បញ្ហានេះ ហើយទ្រង់ដោះស្រាយ រកសមគា ដើម្បីកុំឱ្យគូសត្រូវទាំងសងខាង មានអារម្មណ៍ថាខ្លួនជាអ្នកចាញ់។ នៅត្រង់ចំណុចនេះឯង ដែលគេទុកព្រះបាទជ័យវរ្ម័នទី៧ ជាព្រះមហាក្សត្រទេព[៩]។ តែមកដល់រជ្ជកាល របស់ព្រះបាទជ័យវរ្ម័នទី៨ (១២៤៣-១២៩៥) មានប្រតិកម្មសិវនិយមប្រឆាំងនឹងពុទ្ធសាសនាជាខ្លាំង។ ពួកព្រាហ្មណ៍ មានឥទ្ធពលឡើងវិញ រហូតបង្គាប់ឱ្យកោសលុប រូបចម្លាក់ព្រះពុទ្ធនៅលើជញ្ជាំង និង លើសសរ ក្នុងប្រាសាទនានា ហើយសាង រូបចម្លាក់លិង្គព្រះឥសូរ ឬ តាបសតាំងសីល៍ ជំនួសវិញ។ ការអនុគ្រោះសាជាថ្មីដល់ពួកព្រាហ្មណ៍ គឺដោយសារព្រះបាទជ័យវរ្ម័នទី៨ មានមហេសីមួយរូប ជាកូនព្រាហ្មណ៍បុរោហិត។ រហូតមកដល់រជ្ជកាល ព្រះបាទជ័យវរ្ម័នទី៩ (១៣០៧-១៣៤០) ពួកព្រាហ្មណ៍បុរោហិត នៅមានឥទ្ធិពលខ្លាំង តែពុទ្ធសាសនាថេរវាទ បានរីកសុះសាយណាស់ទៅហើយនៅស្រុកខ្មែរ។ ដែលនាំឱ្យមាន បដិវត្តន៍សាសនាជាថ្មីនៅក្នុងមជ្ឈដ្ឋាន នៃវណ្ណៈមន្ត្រីជាថ្មី ដូច្នេះហើយ បានជាកើតមានព្រឹត្តិការណ៍តាត្រសក់ផ្អែម ដែលជាអ្នកធ្វើឃាតព្រះបាទជ័យវរ្ម័នទី៩ ហើយត្រូវ ពួកមហាសេនាមន្ត្រីលើកឱ្យឡើងសោយរាជ្យបន្តទៅ។

[៩] មហាក្សត្រទេព, មហាក្សត្រមានទេពកោសល្យ។

គេថា ព្រឹត្តិការណ៍តាត្រសក់ផ្អែម វាដូចគ្នានឹងរឿងព្រេងមួយនៅប្រទេសភូមា ដំណាលថា នៅគ.ស. ៩៣១ អ្នកដាំត្រសក់ម្នាក់ឈ្មោះ ញ៉ោងអ៊ូសយ៉ះហាន បានឡើងសោយរាជ្យនៅក្រុងបូកាន ក្រោយពីបានធ្វើឃាត ស្ដេចឈ្មោះសេងទូ ដែលបានលបលួចបេះត្រសក់ របស់ខ្លួន ក្នុងដំណើរ ធ្វើប្រមាញ់នៅក្នុងព្រៃ ហើយដែលខ្លួនពុំបានស្គាល់ថាជាមហាក្សត្រ។

ការលើករឿងព្រេងនោះ មកប្រដូចនឹងព្រឹត្តិការណ៍ នៃតាត្រសក់ផ្អែម វាអាចបកស្រាយបានថា ព្រឹត្តិការណ៍តាត្រសក់ផ្អែម វាគ្រាន់តែជារឿងព្រេង ដែលស្រុកខ្មែរ ទទួលឥទ្ធិពល ក្នុងផ្នែក ពុទ្ធសាសនាហីនយាន ឬ ថេរវាទី ពីស្រុកភូមា។ ដូច្នេះ ព្រឹត្តិការណ៍ តាត្រសក់ផ្អែម វាគ្មានលក្ខណៈ ជាប្រវត្តិសាស្ត្រពិត តែពួកភិក្ខុសង្ឃ និយមថេរវាទីតែងតែនាំគ្នា លើករឿងតាត្រសក់ផ្អែម មកដំណាលតៗគ្នា បែប ជាហេតុប្រវត្តិសាស្ត្រ ដើម្បី ធ្វើស្ពានចំណង រវាងសម័យអង្គរ និង ក្រោយអង្គរ សំរាប់ ពិពណ៌នា យ៉ាងពេញលេញ នូវព្រះរាជពង្សាវតារខ្មែរ ព្រោះចាប់ពី រជ្ជកាលព្រះបាទជ័យវរ្ម័នទី៩ ពួកអ្នកប្រវត្តិសាស្ត្រខ្មែរ ហាក់បីដូចជាមានការលំបាក ក្នុងការចងក្រងពង្សាវតារជាតិ។ តែទោះបីយ៉ាងណា នៅក្នុងព្រះរាជពង្សាវតារខ្មែរ គេទុកព្រឹត្តិការណ៍តាត្រសក់ផ្អែម ជាប្រវត្តិសាស្ត្រជាតិពិត ហើយ

ដាក់ ព្រះបាទស្រ្តសក់ផ្អែម ជាស្ដេចខ្មែរពេញសិទ្ធិ ជាអ្នកបង្កើត សន្ដតិវង្សថ្មី បន្ដពីព្រះបាទជ័យវរ្ម័នទី៩។ ដូច្នេះនៅក្នុងព្រះរាជពង្សាវតារខ្មែរ មិនបានទុក ព្រឹត្តិការណ៍ព្រះបាទស្រ្តសក់ផ្អែមជាបដិវត្តន៍សាសនា និង នយោបាយនោះទេ។ ការប្ដូរពីលទ្ធិទេវជាតិ មក លទ្ធិពុទ្ធគារវតា នៃរាជានិយមខ្មែរ វាគ្រាន់តែប្ដូរ នូវអត្តរូប តែអត្តរស់ នៃរបបវិញ វាស្ថិតនៅទាំងអស់ គឺជារបបសមស្ដ។ របបរាជានិយមពុទ្ធគារវតា លែងទុកវណ្ណៈព្រាហ្មណ៍ ជាវណ្ណៈឯកសិទ្ធិ តែក៏មិនលើក ពុទ្ធសហធម្មិក ជាវណ្ណៈគារវតានោះដែរ។ ស្ដេចពុទ្ធសាសនិក ព្រះអង្គគ្រាន់តែជាអ្នកមានអនុគ្រោះចំពោះព្រះពុទ្ធសាសនា ហើយ ទទួលយកជារាជជំនឿ តែព្រះអង្គ ស្ថិតជាអ្នកត្រួតត្រាលើពុទ្ធសាសនា ក្នុងឋានៈព្រះអង្គជាស្ដេចផ្ដាច់ការ នៅក្នុងព្រះមហានគរ៕